# កំណាយបុរាណវិទ្យានៅភូមិក្រាំងគរ

ភូមិក្រាំងគរ ជាស្ថានីយថ្មីមួយដែលអ្នកស្រាវជ្រាវមុនៗមិនដែលបានដឹងមុនឆ្នាំ២០១០ ដោយសារតែតំបន់នេះ មើលទៅជាវាលស្រែល្វឹងល្វើយ មានតែទួលដែលជាភូមិស្ថានអ្នកស្រុកដោយអន្ទើប៉ុណ្ណោះ។ ប៉ុន្តែតាមរយៈការលួចគាស់កាយរបស់ជនទុច្ចរិតមួយចំនួនបង្ហាញថា នៅតាមទីទួលនានាក្នុងតំបន់នោះមានបង្កប់នូវសំណល់បុរាណជាច្រើន ពេលខ្លះមានទាំងឆ្អឹងមនុស្សទៀតផង។ ភូមិក្រាំងគរមានទីតាំងស្ថិតនៅក្នុងឃុំគរ ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ចម្ងាយប្រហែល១៥គ.មភាគពាយ័ព្យនៃទីក្រុងបុរាណលង្វែក ឬប្រហែល ២០គ.មពីរាជធានីឧត្តុង្គ ដែលជារាជធានីសម័យក្រោយអង្គរ ពីសតវត្សទី១៥ដល់ពាក់កណ្ដាលសតវត្សទី១៩ (រូបលេខ១)។ របកគំហើញនៃស្ថានីយនេះ គឺកើតមានឡើងតាមរយៈនៃការដើរលួចគាស់កកាយរកវត្ថុបុរាណ ហើយអ្នកភូមិបានផ្ដល់ពត៌មានដល់មន្ត្រីនៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដោយក្រោយមកទៀតក្រុមការងាររបស់ក្រសួងបានសហការជាមួយក្រុមស្រាវជ្រាវនៃវិទ្យាស្ថានណារ៉ាចុះពិនិត្យដល់ទីតាំងផ្ទាល់ដែលគេលួចជីក(រូបលេខ២) និងបានប្រទះឃើញវត្ថុបុរាណមួយចំនួន ដែលបន្សល់នៅរាយប៉ាយនៅបរិវេណនោះផងដែរ (រូបលេខ៣)។ ដោយសារយល់ឃើញពីផលប៉ះពាលយ៉ាងខ្លាំងលើស្ថានីយ ក្រសួងវប្បធម៌បានស្នើឱ្យវិទ្យាស្ថានណារ៉ាជួយធ្វើការសិក្សាស្រាវជ្រាវលើស្ថានីយនេះ។

### ការងារស្រាវជ្រាវ និងលទ្ធផល

ការសិក្សាស្រាវជ្រាវនៅភូមិក្រាំងគរបានចាប់ផ្ដើមក្នុងឆ្នាំ២០១០ ដោយបានរៀបចំផែនទីលម្អិតក្នុងភូមិ ការរុករកដោយប្រព័ន្ធរ៉ាដា និងកំណាយបុរាណវិទ្យា។ កំណាយបុរាណវិទ្យាត្រូវបានអនុវត្តចំនួន៤លើក នៅលើទីតាំងសំខាន់២ ទី១គឺនៅតាមទួលខាងលិចភូមិ និងទី២ គឺនៅក្នុងតំបន់ឬបរិវេណបឋមសិក្សាភូមិក្រាំងគរ។ កំណាយនៅទីតាំងទី១តាមទួលខាងលិចភូមិបានផ្ដល់នូវទិន្នន័យតិចតួច ទាក់ទងនឹងការបោះចោលនូវបំណែកភាជន៍ខ្មែរ ថៃ និងចិន ដែលអាចមានអាយុកាលក្នុងឬក្រោយសតវត្សទី១៧(រូបលេខ៤)។ ជាទូទៅវត្ថុទាំងនោះមាននៅក្នុងស្រទាប់ដីជម្រៅប្រហែល៤០ស.ម ទៅ៥០ស.មប៉ុណ្ណោះ នៅក្រោមជម្រៅនេះ គឺជាស្រទាប់ដីខ្សាច់ម៉ត់សុទ្ធ ដូចទៅនៅនឹងវាលស្រែជុំវិញដែរ។ ចំណែកការងារកំណាយនៅលើទីតាំងទី២ គឺមានសារសំខាន់ច្រើន ហើយរណ្ដៅកំណាយ

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា

មានរហូតទៅដល់៧កន្ធែង។ ចំណុចគួរអោយចាប់អារម្មណ៍ក្នុងរណ្តៅទី១គេបានជួបប្រទះនូវស្លាកស្នាមផ្នូរខ្មោចចំនួន១ តែពុំមានសល់ឆ្អឹងទេ គឺមានតែវត្ថុដែលជាគ្រឿងបន្ទុងដែលគេបានកប់ទុកចោល បន្ទាប់ពីការលើកយកឆ្អឹងខ្មោចចេញពីផ្នូរវិញ(រូបលេខ២៥)។ តាមស្លាកស្នាម និងវត្ថុបន្ទុងដូចជា ក្រវិល អង្កាំកែវ និងក្អមទឹក បង្ហាញថាសពត្រូវបានគេដាក់ក្បាលទៅទិសលិច ឈៀងទៅជើងបន្តិច។ វត្ថុបន្ទុងទាំងនោះរួមមាន ក្អមទឹក២នៅលើក្បាល និង១នៅក្រោមជើង ចានថៃ២ ចានចិន២ (រូបលេខ២៦) ក្រវិលសំរិទ្ធ១គូ អង្កាំកែវនៅជុំវិញក្បាលចំនួន១១៨គ្រាប់ (ពណ៌ផ្ទៃមេឃ និងស) កាំបិតតូចធ្វើអំពីដែក២(រូបលេខ២៧)។

ចំណុចសំខាន់មួយទៀត គឺការរកឃើញគំនរបំណែកភាជន៍ កងដៃធ្វើពីដីដុត និងកងដៃធ្វើពីថ្មយ៉ាងច្រើននៅក្នុងរណ្តៅទី៧ ពិសេសគឺឧបករណ៍ធ្វើភាជន៍ (ល្អរនិងក្លឹង) ដែលបង្ហាញថា នៅទាំងតាំងក្នុងបរិវេណសាលារៀននេះ អាចជាកន្លែងសិប្បកម្មផលិតកុលាលភាជន៍ និងគ្រឿងផ្សេងៗមួយចំនួនទៀតក្នុងសម័យបុរាណទៀតផង (រូបលេខ២៨)។

**កាលបរិច្ឆេទ**

តាមរយៈការសិក្សាប្រៀបធៀបវត្ថុសិល្បៈ ពិសេសភាជន៍ចិននិងថៃដែលរកបានតាមទីតាំងនីមួយៗ និងពីផ្នូរក្នុងរណ្តៅទី១ រួមមានចានចិនមានស្រទាប់រលោងពណ៌បៃតង (Celadon) និងចានថៃមកពីស្រីសត្ចណាលៃ (Sri Satchanalai) បង្ហាញជាបណ្តោះអាសន្នថា ស្ថានីយនេះដែលមានវត្ថុទាំងនេះ គឺស្ថិតនៅក្នុងពាក់កណ្តាលសតវត្សទី១៥។[១] តាមការសិក្សាវិភាគបែបវិទ្យាសាស្រ្តលើគ្រប់អង្កាំដែលបានពីកំណាយបង្ហាញថា វាមានសមាសធាតុស្មើដូចគ្នាទាំងស្រុងទៅនឹងអង្កាំដែលផលិតនៅប្រទេសចិន ចាប់ពីសតវត្សទី១២ ដែលគេហៅថាអង្កាំកែវលាយសំណប៉ូតាស្យូម (Potassium Lead Glass Bead)។[២] បច្ចេកទេសផលិតអង្កាំ និងជំនួញអង្កាំបែបនេះបាននាំចូលកម្ពុជា និងប្រទេសអាស៊ីអាគ្នេយ៍តាំងពីសតវត្សទី១២។[៣]

របកគំហើញថ្មីនេះ ជាភស្តុតាងយ៉ាងសំខាន់សម្រាប់អ្នកស្រាវជ្រាវក្នុងការសិក្សាអោយកាន់តែច្បាស់អំពីប្រវត្តិសាស្រ្តកម្ពុជានាសម័យក្រោយអង្គរ ជាពិសេសគឺសិក្សាលើ

[១] Yuni Sato 2013:19

[២] Tomomi Tamura 2013:39

[៣] Francis, P. 2002

ព្រឹត្តិការណ៍នានាដែលកើតមាននៅជុំវិញតំបន់នោះ និងទំនាក់ទំនងជាមួយអតីតរាជធានីលង្វែក និងឧត្តុង្គ។

នេះជាដំណាក់កាលដំបូងនៃការស្រាវជ្រាវ និងកំណាយនៅស្ថានីយភូមិក្រាំងគរ ហើយលទ្ធផលបណ្តោះអាសន្នបានផ្តល់នូវពត៌មាននៃការកប់សព និងកន្ទែងដែលអាចជាសិប្បកម្មផលិតកុលាលភាជន៍ផងដែរ។ វាទាមទារឱ្យមានការធ្វើកំណាយបន្ថែមដើម្បីប្រមូលយកទិន្នន័យក្នុងការបកស្រាយឱ្យបានច្បាស់លាស់អំពីបុរាណដ្ឋានមួយនេះ។

## ឯកសារយោង


Francis, P.

2002. Asia´s Maritime Bead Trade, University of Hawaii Press

Tomomi Tamura.

2013. *Scientific Study and Conservation Treatment of Artifacts Excavated from the Krang Kor Site*, in the Discovery of the Krang Kor Site-Exploring into Post-Angkor Period, NRICP and MCFA, Japan.

Yuni Sato.

2013. *Study of Krang Kor Site: Report on the Excavation and Its Artifact*, in the Discovery of the Krang Kor Site-Exploring into Post-Angkor Period, NRICP and MCFA, Japan.


អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា




រូបលេខ១៖ ផែនទីទាំងស្ថានីយភូមិក្រាំងគរ



រូបលេខ២៖ ការចុះពិនិត្យមើលស្ថានីយ និងវត្ថុ



រូបលេខ៣៖ វត្ថុសិល្បៈដែលគេលួចគាស់



រូបលេខ៤៖ កំណាយនៅទីតាំងទី១ រណ្ដៅទី១



រូបលេខ៥៖ ស្នាមផ្នូរក្នុងរណ្ដៅទី៣



រូបលេខ៦៖ ភាជន៍ខ្មែរ ចិន និងថៃ ក្នុងផ្នូររណ្ដៅ



រូបលេខ៧៖ អង្កាំ ក្រវិល និងកាំបិត



រូបលេខ៨៖ ឧបករណ៍ធ្វើភាជន៍ (ក្លឹង)

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា

# សកម្មភាពទូទៅនៃការធ្វើកំណាយ

















អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា